**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ : ១.២.៥នស/សជ

ភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៩

## សេចក្តីណែនាំ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

**ជំរាបមក**

**លោកស្រី អស់លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី-ខេត្ត**

**កម្មវត្ថុ** : គោលការណ៍ណែនាំស្តីពីការចុះបញ្ជីដីដែលតុលាការបដិសេធវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ។

**យោង** : - លិខិតលេខ ១៥៧ ដនសស/ស.ជ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តកំពត ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកស្រី អស់លោកប្រធានមន្ទីរឱ្យបានជ្រាបថា : នាពេលកន្លងមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ បានកត់សំគាល់ឃើញថា មានក្បាលដីមួយចំនួនដែលរដ្ឋបាលសុរិយោដីបានចុះបញ្ជី និងចេញប័ណ្ណរួចហើយ ត្រូវបានតុលាការសំរេចបដិសេធប័ណ្ណចោល ដោយករណីខ្លះ ត្រូវបានតុលាការសំរេចបដិសេធសិទ្ធិរបស់ម្ចាស់ដី ដែលមានចារឹកក្នុងឯកសារសុរិយោដី តែអត្តសញ្ញាណក្បាលដីមិនផ្លាស់ប្តូរ និងមានករណីខ្លះទៀត ត្រូវបានតុលាការសំរេចបដិសេធសិទ្ធិ ដោយមូលហេតុការផ្តល់ប័ណ្ណខុសនីតិវិធី ឬកំណត់អត្តសញ្ញាណក្បាលដីមិនត្រឹមត្រូវ ។ ប៉ុន្តែប័ណ្ណដីដើមទាំងនោះ ពុំត្រូវបានតុលាការធ្វើការដកហូតពីអ្នកចាញ់ក្តី ឬអ្នកដែលកំពុងកាន់កាប់ឡើយ ។

ដូចនេះ ដើម្បីអនុវត្តសេចក្តីសំរេចរបស់តុលាការឱ្យមានប្រសិទ្ធភាព ក្រសួងសូមធ្វើការណែនាំដូចខាងក្រោម :

១. ករណីតុលាការសំរេចបដិសេធសិទ្ធិរបស់បុគ្គលដែលចារឹកក្នុងឯកសារ តែអត្តសញ្ញាណក្បាលដីមិនផ្លាស់ប្តូរ :

ករណីនេះកើតឡើងច្រើន ដោយអ្នកមានឈ្មោះក្នុងប័ណ្ណ មិនព្រមប្រគល់ប័ណ្ណដីដើមឱ្យតុលាការ នៅពេលខ្លួនចាញ់ក្តី ធ្វើឱ្យរដ្ឋបាលសុរិយោដីដែលមានសមត្ថកិច្ចផ្ទេរសិទ្ធិ/កាត់ឈ្មោះ ពីម្ចាស់ដើម ទៅអ្នកឈ្នះក្តី ពុំអាចធ្វើបាន ។ ដើម្បីដោះស្រាយករណីនេះ រដ្ឋបាលសុរិយោដីត្រូវអនុវត្តនីតិវិធីចេញប័ណ្ណទុតិយតា/តតិយតា រួចយកប័ណ្ណនេះមកធ្វើចរន្តការផ្ទេរសិទ្ធិ/កាត់ឈ្មោះ តាមអំណាចសាលក្រម/សាលដីការបស់តុលាការ ជូនអ្នកឈ្នះក្តីតែម្តង ។

២. ករណីផ្តល់ប័ណ្ណខុសនីតិវិធី ឬកំណត់អត្តសញ្ញាណក្បាលដីមិនបានត្រឹមត្រូវ :

(១) មន្ទីរត្រូវធ្វើសេចក្តីជូនដំណឹងដល់សាធារណៈជន អំពីការបដិសេធប័ណ្ណដោយតុលាការ ដើម្បីឱ្យអ្នកកាន់កាប់ប័ណ្ណដីទាំងនោះបានជ្រាប និងប្រគល់ប័ណ្ណឱ្យរដ្ឋបាលសុរិយោដី យកមកបោះត្រាមោឃភាព រក្សាទុក (ដូចមានគំរូភ្ជាប់) ។

**អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្រាបែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ**

Tel : (855) 023 215 659-215 660 . Fax : (855) 023 215 277 . e-mail : im. c . lim. @ Camnet. Com. Kh

(២) នៅលើកំណត់ហេតុអង្កេតដី ឬទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងនៅត្រង់ខ្ទង់សេចក្តីផ្សេងៗ លើប័ណ្ណ និងលើសន្លឹកសៀវភៅគោលបញ្ជីដីធ្លី ឬខណ្ឌនៃសៀវភៅចុះបញ្ជីអចលនវត្ថុ ដែលត្រូវបានតុលាការបដិសេធចោល មន្ទីរត្រូវសរសេរបញ្ជាក់ថា "**ត្រូវបានបដិសេធចោលតាមសាលក្រម/សាលដីកាលេខ ..... ចុះថ្ងៃ ..... របស់តុលាការ .....**" រួចត្រូវឆូតខ្វែងដោយទឹកក្រហមនៅលើសន្លឹកសៀវភៅគោលបញ្ជីដីធ្លី ឬខណ្ឌនៃសៀវភៅចុះបញ្ជីអចលនវត្ថុនោះ ។

(៣) មន្ទីរត្រូវកសាងឯកសារចេញប័ណ្ណថ្មីជូនអ្នកទទួលបានសិទ្ធិតាមការសំរេចរបស់តុលាការ ។

អាស្រ័យហេតុនេះ សូមលោកស្រី អស់លោកប្រធានមន្ទីរជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារណែនាំខាងលើ ឱ្យមានប្រសិទ្ធភាព ។

សូមលោកស្រី អស់លោកប្រធានមន្ទីរ ទទួលនូវការរាប់អានអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

<u>ចម្លងជូន</u> :

- អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ
- គ្រប់សាលារាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ